# គម្រោងពង្រឹងសមត្ថភាព
# សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
# ក្នុងវិស័យកសិកម្ម នៅប្រទេសកម្ពុជា



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ក.ស.ក)

ជាមួយការគាំទ្របច្ចេកទេសពី

អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

Food and Agriculture
Organization of the
United Nations

Humanitarian Aid
and Civil Protection

# សាវដា

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្ម ហើយ៨០% នៃចំនួនប្រជាជនសរុបរស់នៅ និងធ្វើការនៅជនបទ។ វិស័យកសិកម្មបានរួមចំណែកប្រហែល១/៣ នៃផលិតផលក្នុងស្រុកសរុបរបស់ ប្រទេសកម្ពុជា និងបានរួមចំណែកយ៉ាងសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និង បង្កើនសន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ។ ទោះបីយ៉ាងណាក៏ដោយ ផលិតភាពកសិកម្មនៅកម្ពុជា នៅមានកម្រិតទាបនៅឡើយបើធៀប នឹងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសអង្ករ។ មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និង គ្រោះមហន្តរាយ គឺជាកត្តាដែលតែងតែបង្ករផលប៉ះពាល់ដល់ការផលិត។

## ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

សំដៅដល់កម្មវិធី និងសកម្មភាពដែលបានកំណត់ដើម្បី បញ្ចៀស ឬ *កំរិត* និង គិតទុកជាមុន ទៅលើផលប៉ះពាល់ធ្ងន់ធ្ងរ នៃមុខសញ្ញាគ្រោះថ្នាក់។

គោលបំណងនៃ ការការពារ *ការកាត់បន្ថយ* និង ការត្រៀមបង្ការគ្រោះមហន្តរាយនេះ គឺដើម្បីកាត់បន្ថយចំនួនមុខសញ្ញា គ្រោះថ្នាក់ដែលអាចប្រែក្លាយទៅជាគ្រោះមហន្តរាយ និងកាត់បន្ថយការខូចខាត និងខាតបង់។

ស្ទើររៀងរាល់ឆ្នាំទឹកជំនន់ និងរាំងស្ងួត បណ្តាលឱ្យ មានការខូចខាត និងបាត់បង់ធ្ងន់ធ្ងរ។ បញ្ហានេះវាមិន គ្រាន់តែគំរាមកំហែងដល់សន្តិសុខស្បៀង និងកាត់បន្ថយកំរិតជីវភាពរស់នៅប៉ុណ្ណោះទេ ប៉ុន្តែធ្វើឱ្យស្ថានភាពអាហាររូបត្ថម្ភ របស់កសិករ ខ្នាតតូចកាន់តែធ្ងន់ធ្ងរឡើង។ ផលប៉ះពាល់នៃការផ្លាស់ប្តូរ អាកាសធាតុ នឹងធ្វើឱ្យប្រព័ន្ធស្បៀងអាហារកាន់តែតាន តឹងបន្ថែមទៀត។





*ការរៀបចំផែនការសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (ផ្ទេង)*

# អ្នកពាក់ព័ន្ធនិងអ្នកទទួលផលប្រយោជន៍

**គំរោងនេះនិងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់៖**

-កសិករចំនួន ៣០០គ្រួសារ នៅក្នុងខេត្តកំពង់ស្ពឺ និងឧត្តរមានជ័យ

-ប្រជាជននិងជាពិសេសក្រុមកសិករប្រើប្រាស់ទឹកចំនួន ២២៩១ គ្រួសារ ពីការស្តារប្រឡាយទឹកក្នុងខេត្តកំពង់ស្ពឺ។

-បុគ្គលិកចំនួន ២៥០នាក់ មកពីនាយកដ្ឋានផ្សេងៗ នៃក្រសួងកសិកម្ម រាប់ទាំងថ្នាក់ជាតិ និងខេត្តគោលដៅ ព្រមទាំងមន្ទីរធនធានទឹកខេត្ត កំពង់ស្ពឺ។



*វគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករ*

## លទ្ធផលរំពឹងទុក

**បរិបទការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** បានបញ្ចូលទៅក្នុងផែនការសកម្មភាពអាទិភាពរបស់ក្រសួងកសិកម្ម សម្រាប់ការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ព្រៃឈើ និងជលផល ឆ្នាំ២០១៤-២០១៨។ ផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម បានបង្កើតសម្រាប់ខេត្តឧត្តរមានជ័យ។

**វគ្គបណ្តុះបណ្តាល** បានធ្វើនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងសហគមន៍ ដើម្បីធានាថា អ្នកសរសេរគោលនយោបាយ ភ្នាក់ងាររបស់រដ្ឋាភិបាល និងប្រជាកសិករ ទទួលបាន ចំណេះដឹងក្នុងការដាក់បញ្ចូល បរិបទការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយទៅក្នុងវិស័យកសិកម្ម។

© FAO, 2015

**បច្ចេកទេសកសិកម្មសមស្រប** បានចងក្រង ពិសោធន៍ កែតម្រូវ និង ផ្សព្វផ្សាយ ក្នុងខេត្តកំពង់ស្ពឺនិងឧត្តរមានជ័យ (បច្ចេកទេសកសិកម្មដែលមានភាពធន់នឹងអាកាសធាតុ និងគ្រោះមហន្តរាយ ដូចជាជីកំប៉ុស្ត ការត្រងទឹកភ្លៀងដោយប្រើដំបូល និងប្រព័ន្ធដំណក់ទឹក ជាដើម)។

**ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ** ដែលមានស្រាប់នៅក្នុង ឃុំចំនួន២ ក្នុងខេត្តកំពង់ស្ពឺ បានជួសជុល និងស្តារឡើងវិញ។

**ក្រុមកសិករប្រើប្រាស់ទឹក** បានបង្កើត ដើម្បីបង្កើនការគ្រប់គ្រងនៃប្រព័ន្ធធារាសាស្ត្រ (ឧទាហរណ៍ ការត្រួតពិនិត្យ និង ការថែទាំជាប្រចាំ)។




*សកម្មភាពសិក្សាពីគំរោងស្តារប្រឡាយនៅខេត្តកំពង់ស្ពឺ*


**ទំនាក់ទំនង៖**

**ការិយាល័យអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ**

ផ្ទះលេខ៥ ផ្លូវលេខ៣៧០សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ។

**ទូរស័ព្ទលេខ** +៨៥៥ (0) ២៣ ២១៦ ៥៦៦

**អ៊ីមែល៖** FAO-KH@fao.org

អ្នកស្រី សេង គឹមហ៊ាន (ទីប្រឹក្សាបច្ចេកទេស និងអ្នកសម្របសម្រួល)